054551

សាធារណរដ្ឋខ្មែរ

CAMB.
FILE / SUBJ.
DATE / SUB-CAT.
1966
1972
1972

# ច្បាប់សារព័ត៌មាន

# CODE DE LA PRESSE

ផ្សាយចេញពីក្រសួងឃោសនាការ

# បញ្ញត្តិ

## ប្រធានាធិបតី
## នៃ
## សាធារណរដ្ឋខ្មែរ

ធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ ជាអាទិ៍ត្រង់មាត្រា៧។
ញ្ញត្តិលេខ ១-៧១-បរ ចុះថ្ងៃទី ១៨ ខែ តុលា
ប់គ្រងបញ្ហាទាំងឡាយណា ដែលនៅក្រោមអំណាច

ត្រី បានយល់ព្រម ។

បង្គាប់ដូចមានខាងក្រោមនេះ

យ.- ត្រូវប្រកាសឲ្យប្រើនូវច្បាប់តាំងបទបញ្ញា
នាសាធារណរដ្ឋខ្មែរ ដែលមានឈ្មោះថា "ច្បាប់
ចមានបទបញ្ញត្តិភ្ជាប់នូវបច្ចុប្បន្នបញ្ញត្តិនេះ ។
- បញ្ញត្តិនេះ ត្រូវប្រកាសជាភាពប្រញាប់ ។

27 June 1972

ធ្វើនៅភ្នំពេញថ្ងៃទី ២៧ ខែ មិថុនា គ.ស. ១៩៧២

ហត្ថលេខា: លន់-នល់

# ច្បាប់សារពត៌មាន

## ជំពូក ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១-**

ការសំដែងគំនិតតាមសារពត៌មានធ្វើបានដោយសេរី។ ការពិនិត្យសារពត៌មានមុនការចេញផ្សាយ ត្រូវហាមឃាត់មិនឱ្យមាន ។

**មាត្រា ២-**

ការប្រើសេរីភាពសារពត៌មាន មិនត្រូវប៉ះពាល់កិត្តិយសបុគ្គល សន្តិសុខជាតិ ឬ ទំនៀមទំលាប់ល្អ ។

ពលរដ្ឋរាល់រូប ត្រូវចៀសវាងកុំប្រើសិទ្ធិនេះដោយរំលោភ ដើម្បីធ្វើឱ្យខូចរបៀបរៀបរយសាធារណៈ ។

**មាត្រា ៣-**

ការប្រើសេរីភាពសារពត៌មាននឹងអាចផ្អាកបាន តែក្នុងករណីដែលមានភាពអាសន្ន មានវិក្រិតិកាល ឬ បើមានប្រកាសថា ប្រជាជាតិឋិតក្នុងភយន្តរាយ ឬ ក្នុងភាពសង្គ្រាម ក្នុងលក្ខខ័ណ្ឌ ដូចមានចែងក្នុងមាត្រា ២២ នៃរដ្ឋធម្មនុញ្ញ ។

មាត្រា ៤-

ច្បាប់បច្ចុប្បន្ននេះ រៀបចំរបបសារព័ត៌មាន ក្នុង សាធារណរដ្ឋខ្មែរ ។

## ជំពូក ២

## អំពីរោងពុម្ព និង បណ្ណាគារ

មាត្រា ៥-

រោងពុម្ព និង បណ្ណាគារបើកបានដោយសេរី ។ ក៏ប៉ុន្តែ មុខរបររបស់អ្នកបោះពុម្ពផ្សាយ ត្រូវហាមឃាត់ចំពោះជនបរទេស។

មាត្រា ៦-

អត្ថបទជាលាយលក្ខណ៍អក្សរគ្រប់បែបយ៉ាងផ្សាយជា សាធារណៈ លើកលែងតែលិខិតបោះពុម្ពរាយរងដែលគ្មានសារៈ សំខាន់ ដូចជាប័ណ្ណអញ្ជើញ នាមប័ណ្ណ ស្រោមសំបុត្រ លិខិតបោះពុម្ពខាងរដ្ឋបាលជាដើម ត្រូវមានការបញ្ជាក់ឈ្មោះនិងអាសយដ្ឋាន រោងពុម្ព ។ ការប្រព្រឹត្តិផ្ទុយពីលក្ខខណ្ឌនេះ ត្រូវពិន័យជាប្រាក់ចំនួន ពី ប្រាំពីរពាន់ "៧.០០០រ០០" ដល់ប្រាំពីរម៉ឺន "៧០.០០០រ០០" រៀល ចំពោះអ្នកបោះពុម្ព ។

ការចាត់ចែកក្រដាសបោះពុម្ពទាំងឡាយ ដែលពុំមាន ការបញ្ជាក់ដូចមាននៅក្នុងកថាខណ្ឌខាងលើនេះ ត្រូវហាមឃាត់ ហើយជនណាដែលប្រព្រឹត្តល្មើសនឹងការហាមឃាត់នេះ ត្រូវទទួលទណ្ឌកម្មដូចគ្នា ។

ទោសគុកពីប្រាំមួយខែ "៦" ខែទៅដល់មួយឆ្នាំ និងអាចសំរេចចំពោះអ្នកបោះពុម្ព ឬ អ្នកចែក ប្រសិនបើ សាមីជនក្នុងរយៈពេលដប់ពីរ "១២" ខែមុនត្រូវជាប់គុកទោសដោយបទល្មើសដូចគ្នា ។

o

o o

## ជំពូក ៣

## អំពីសារពត៌មាន ទស្សនាវដ្ដី

## សិទ្ធិនៃការផ្សាយ បណ្ណាធិការ ពាក្យបណ្ដឹង

## និងការប្រគល់ទុក

### មាត្រា ៧-

សារពត៌មាន ឬ ទស្សនាវដ្ដីទាំងអស់ ត្រូវមានម្ចាស់ ចាងហ្វាងនៃការផ្សាយ និង អ្នកនិពន្ធនាយក ។

ម្ចាស់សារពត៌មាន អាចកាន់មុខងារជាចាងហ្វាងនៃការផ្សាយផង ឬ ជាអ្នកនិពន្ធនាយកផង ។

កាលបើចាងហ្វាងនៃការផ្សាយមានអភ័យឯកសិទ្ធិសភា

ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៥៤ នៃរដ្ឋធម្មនុញ្ញ ចាងហ្វាងនៃការផ្សាយត្រូវតែងតាំងសហចាងហ្វាងនៃការផ្សាយមួយរូប ដែលជ្រើសរើសក្នុងចំណោមជនដែលគ្មានអភ័យឯកសិទ្ធិសភា ។

មាត្រា ៨-

សារពត៌មាន ឬ ទស្សនាវដ្តីទាំងអស់ ដែលបោះពុម្ពផ្សាយជាភាសាជាតិ និងអាចផ្សាយបាន បន្ទាប់ពីបានដាក់ពាក្យជូនដំណឹងជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងឃោសនាការ ស្របតាមបញ្ញត្តិទាំងឡាយនៃច្បាប់នេះរួចហើយ ។

មាត្រា ៩-

ម្ចាស់សារពត៌មាន ចាងហ្វាងនៃការផ្សាយ សហចាងហ្វាងនៃការផ្សាយ និងអ្នកនិពន្ធនាយក ត្រូវ៖

- ក- មានសញ្ជាតិជាខ្មែរ
- ខ- មានអាយុ ២៥ ឆ្នាំយ៉ាងតិច នៅកាលបរិច្ឆេទដាក់ពាក្យបណ្តឹង ។
- គ- មានសិទ្ធិជាពលរដ្ឋ ហើយពុំមានជាប់ទោសពីបទអ្វីមួយឡើយ ។ ចាងហ្វាងនៃការផ្សាយ សហចាងហ្វាងនៃការផ្សាយនិងអ្នកនិពន្ធនាយក ត្រូវមាន

សញ្ញាប័ត្រខាងវិជ្ជាសារពត៌មាន ឬ មធ្យមសិក្សាប័ត្រច្បាប់ ឬសញ្ញាប័ត្រណាមួយដែលមានតម្លៃស្មើគ្នា ឬ លិខិតបញ្ជាក់ថា

ខ្លួនបានធ្វើការជាអ្នកនិពន្ធចំនួនរយៈពេលយ៉ាងតិចពីរឆ្នាំ នៅ
ក្នុងសារពត៌មានណាមួយ ឬ ប្រចាំសារពត៌មាន ឬ ក្នុងទីភ្នាក់
ងារពត៌មាន ឬមួយមិនទិតបញ្ជាក់ថា ខ្លួនធ្លាប់បានធ្វើជាមន្ត្រីរដ្ឋ
ការនៃក្របខ័ណ្ឌជាន់ខ្ពស់ ជាចាងហ្វាង ឬ អ្នកនិពន្ធនាយកនៃ
សារពត៌មាន ឬ ទស្សនាវដ្ដីណាមួយ មានរយៈពេលយ៉ាងតិចមួយ
ឆ្នាំ ។

មាត្រា ១០-

ពាក្យបណ្ដឹងចំពោះទីស្ដីការនៃរដ្ឋមន្ត្រីក្រសួងឃោសនាការ
ដែលមានចែងក្នុងមាត្រា ៨ ត្រូវធ្វើដោយចាងហ្វាងនៃការ
ផ្សាយ ។

សំណុំរឿងពាក្យជូនដំណឹងនេះត្រូវមាន :

១- ពាក្យបណ្ដឹងជា ៣ ច្បាប់ ដែលមានចុះហត្ថលេខា
បញ្ជាក់នាមច្បាប់របស់ចាងហ្វាងនៃការផ្សាយ ដែលមាន
បញ្ជាក់ដូចតទៅ :

- ឈ្មោះសារពត៌មាន ឬ ទស្សនាវដ្ដី របៀបផ្សាយ
ទោលចំណង និងបន្ទាត់នយោបាយនៃសារពត៌មាន ,

- នាម អត្តសញ្ញាណប័ណ្ណ និង ភាសយដ្ឋាន នៃម្ចាស់
សារពត៌មាន ,

- នាម និង អត្តសញ្ញាណប័ណ្ណ និង ភាសយដ្ឋាន នៃ
ចាងហ្វាងនៃការផ្សាយ លោកចាងហ្វាងនៃការផ្សាយ "បើសិន
ជាមាន" និង អ្នកនិពន្ធនាយក

- ចំនួនមូលធន ដែលបានកំណត់ដោយម្ចាស់សារពត៌មាន
- ឈ្មោះ និង អាសយដ្ឋាននៃរោងពុម្ពដែលបោះពុម្ព សារពត៌មាន ឬ ទស្សនាវដ្តី ។

២- លិខិតបញ្ជាក់ទីលំនៅរបស់ម្ចាស់សារពត៌មាន របស់ចាងហ្វាងនៃការផ្សាយ សហចាងហ្វាងនៃការផ្សាយ "បើសិនជាមាន" និង អ្នកនិពន្ធនាយក ។

៣- សេចក្តីចម្លងសំបុត្រកំណើត និង រូបថត ៣ សន្លឹក របស់ម្ចាស់សារពត៌មាន របស់ចាងហ្វាងនៃការផ្សាយ សហចាងហ្វាងនៃការផ្សាយ " បើសិនជាមាន "និងអ្នកនិពន្ធនាយក ។

៤- សេចក្តីចម្លងសញ្ញាប័ត្រឬលិខិតបញ្ជាក់តាមច្បាប់ អំពីសំអាងដែលមានចែងក្នុងមាត្រា ៩ កថាខ័ណ្ឌចុងក្រោយ ។

៥- សេចក្តីចម្លងសំបុត្រថ្កោលទោស ដែលមានកាលបរិច្ឆេទមិនលើសពីបីខែរបស់ម្ចាស់សារពត៌មាន ចាងហ្វាងនៃការផ្សាយ សហចាងហ្វាងនៃការផ្សាយ "បើសិនជាមាន" និង អ្នកនិពន្ធនាយក

៦- សេចក្តីចម្លងកិច្ចសន្យាដែលសមាគម ប្រសិនបើសារពត៌មាន ឬ ទស្សនាវដ្តី ត្រូវបោះពុម្ពផ្សាយចេញពីក្រុមហ៊ុន ឬ សមាគម ។

ការបញ្ជាក់ក្នុងលិខិតទាំងឡាយខាងលើ ដែលធ្វើឡើងដោយពុំត្រឹមត្រូវតាមការពិតនិងត្រូវទទួលទណ្ឌកម្មតាមមាត្រា ៤៦ នៃច្បាប់នេះ ។

## មាត្រា ១១-

លុះបានទទួលសំណុំរឿងគ្រប់សព្វនៃពាក្យជូនដំណឹងដូចមានចែងក្នុងមាត្រា ១០ រួចហើយ រដ្ឋមន្ត្រីក្រសួងឃោសនាការត្រូវឱ្យដំណឹងទៅអ្នកដើមបណ្ដឹងថា បានទទួលពាក្យជូនដំណឹងនោះហើយ ។

ក្នុងរយៈពេលមួយខែយ៉ាងយូរបំផុត បន្ទាប់ពីការទទួលសំណុំរឿងសព្វគ្រប់នៃពាក្យជូនដំណឹងហើយ រដ្ឋមន្ត្រីក្រសួងឃោសនាការ ចេញបង្កាន់ដៃមួយច្បាប់ ដែលមានបញ្ជាក់ថា សំណុំរឿងនៃពាក្យបណ្ដឹងនេះ ត្រឹមត្រូវតាមបទបញ្ញត្តិច្បាប់ជាធរមានហើយ ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងឃោសនាការ មិនបានចេញបង្កាន់ដៃឱ្យទេ ឬ មួយមិនបានឱ្យដំណឹងអំពីការមិនទទួលទុកពាក្យជូនដំណឹងជាបានការ ក្នុងរយៈពេលមួយខែដែលបានកំណត់ក្នុងកថាខណ្ឌមុននេះ សំណុំរឿងនៃពាក្យជូនដំណឹង នឹងត្រូវចាត់ទុកជាបានការដោយឯកឯងតែម្ដង ។

សេចក្ដីសំរេចនៃរដ្ឋមន្ត្រីក្រសួងឃោសនាការ អំពីការបដិសេធ ត្រូវមានបញ្ជាក់អំពីមូលហេតុនៃការបដិសេធនេះ ។

## មាត្រា ១២ -

ក្នុងករណីនៃការបដិសេធដោយរដ្ឋមន្ត្រីក្រសួងឃោសនាការ អ្នកដើមបណ្ដឹងមានសិទ្ធិប្ដឹងសារទុក្ខទៅក្រុមប្រឹក្សារដ្ឋ ។

ក្រុមប្រឹក្សារដ្ឋវិនិច្ឆ័យលើករណីនេះ ក្នុងរយៈពេល ៣០ ថ្ងៃ ។ ក្នុងករណីដែលក្រុមប្រឹក្សារដ្ឋ បដិសេធសេចក្តីសំរេចរបស់រដ្ឋមន្ត្រីក្រសួងឃោសនាការ សំណុំរឿងនៃពាក្យជូនដំណឹងនៃចាងហ្វាងនៃការផ្សាយ នឹងត្រូវចាត់ទុកជាបានការចាប់តាំងពីកាលបរិច្ឆេទនៃការសំរេចរបស់ក្រុមប្រឹក្សារដ្ឋ។

មាត្រា ១៣ –

វិនានុប្បវត្តិ ឬ ទស្សនាវដ្តី ត្រូវចេញផ្សាយក្នុងរយៈពេលមួយរយថ្ងៃយ៉ាងយូរបំផុត ចាប់តាំងពីកាលបរិច្ឆេទដែលសំណុំរឿងនៃពាក្យជូនដំណឹងបានត្រូវចាត់ទុកជាបានការ ។ ផុតពីរយៈពេលនេះទៅ សំណុំរឿងនៃពាក្យជូនដំណឹងនឹងត្រូវចាត់ទុកជាមោឃៈ ដោយឯកឯង ។

មាត្រា ១៤ –

ត្រូវចាត់ទុកថាជាការបញ្ឈប់ការផ្សាយដោយចេតនា និងជាស្ថាពរពីសំណាក់នៃវិនានុប្បវត្តិ ឬ ទស្សនាវដ្តីដែលបានផ្អាកការផ្សាយចំនួនបីខែជាប់គ្នា ក្នុងការផ្សាយចំពោះវិនានុប្បវត្តិ ឬដែលបានផ្អាកការផ្សាយចំនួន៤លេខជាប់គ្នា ចំពោះទស្សនាវដ្តី ។

មាត្រា ១៥ –

នៅទំព័រក្រៅ គ្រប់ច្បាប់នៃវិនានុប្បវត្តិ ឬ ទស្សនាវដ្តី ត្រូវមានឈ្មោះពុម្ព :

- នាមរបស់ចាងហ្វាងនៃការផ្សាយ សហចាងហ្វាងនៃការផ្សាយ បើសិនជាមាន និង អ្នកនិពន្ធនាយក ,

- អាសយដ្ឋាន នៃ សារពត៌មាន ,
- ឈ្មោះនិងអាសយដ្ឋាននៃរោងពុម្ព ,
- តម្លៃលក់ក្នុងមួយលេខ និង តម្លៃជាវ ,
- ចំនួនច្បាប់បោះពុម្ព ក្នុងមួយលេខ ៗ ។

## មាត្រា ១៦ -

មុនការចែកផ្សាយ ចាងហ្វាងនៃការផ្សាយ ឬសហចាងហ្វាងនៃការផ្សាយ ត្រូវយកសារពត៌មានដែលមានចុះហត្ថលេខានិងត្រារបស់ខ្លួនទៅតំកល់ទុកតាមចំនួនខាងក្រោមនេះ

- ដប់ "១០" ច្បាប់ ទៅក្រសួងឃោសនាការ ,
- ពីរ "២" ច្បាប់ ទៅក្រសួងមហាផ្ទៃ ,
- ពីរ "២" ច្បាប់ ទៅរដ្ឋអាជ្ញានៃសាលាដំបូងភ្នំពេញ
- ពីរ "២" ច្បាប់ ទៅបណ្ណាល័យជាតិ ។

## មាត្រា ១៧ -

ក្នុងករណីដែលមានការផ្លាស់ប្តូរចាងហ្វាងនៃការផ្សាយ អ្នកនិពន្ធនាយក ការិយាល័យនិពន្ធ រោងពុម្ព ឬ មូលធន ចាងហ្វាងនៃការផ្សាយ ត្រូវជំរាបដំណឹងនេះទៅក្រសួងឃោសនាការ ក្នុងរយៈពេល១៥ថ្ងៃយ៉ាងតិច មុនការផ្លាស់ប្តូរនេះ ។

ចំពោះការតំឡើងប្រាក់មូលធន ចាងហ្វាងនៃការ

ផ្សាយ ត្រូវផ្តល់លិខិតបញ្ជាក់ទាំងឡាយ អំពីប្រភពនៃការតម្លើងប្រាក់មូលធននេះ ។

សារព័ត៌មាន ឬ ទស្សនាវដ្តី អាចបន្តការផ្សាយរបស់ខ្លួនតទៅទៀតបាន លុះត្រាតែបានបំពេញលក្ខខ័ណ្ឌដូចមានចែងខាងលើនេះ ។

មាត្រា ១៨ -

ប្រជាពលរដ្ឋខ្មែរ ដែលចង់ផ្សាយសារព័ត៌មាន ឬ ទស្សនាវដ្តី ជាភាសាបរទេស ត្រូវមានសេចក្តីអនុញ្ញាតជាមុន អំពីរដ្ឋមន្ត្រីក្រសួងឃោសនាការ ។

សេចក្តីអនុញ្ញាតនេះ ដែលចេញឱ្យតាមសេចក្តីសំរេចក្រសួងអាចដកហូតវិញបានគ្រប់ពេលវេលា ។

មាត្រា ១៩ -

ជនបរទេសរាល់រូប ដែលមានបំណងចេញផ្សាយសារព័ត៌មាន ឬ ទស្សនាវដ្តី ក្នុងសាធារណរដ្ឋខ្មែរត្រូវគោរពតាមបទបញ្ញត្តិនៃច្បាប់នេះ លើកលែងតែកថាខ័ណ្ឌទីពី សញ្ជាតិចេញ ។ក៏ប៉ុន្តែ សេចក្តីអនុញ្ញាតនៃការផ្សាយនឹងត្រូវចេញឱ្យតាមប្រកាសរដ្ឋមន្ត្រីក្រសួងឃោសនាការ បន្ទាប់ពីមានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ។

o ᵒ o

# ជំពូក ៥

## សិទ្ធិ និង ភារកិច្ចនៃសារពត៌មាន

**មាត្រា ២០ –**

សារពត៌មាន មានសិទ្ធិរក្សាទុកនូវអាថ៌កំបាំង អំពីប្រភពពត៌មានរបស់ខ្លួន ។

**មាត្រា ២១ –**

សារពត៌មាន មានសេរីភាពខាងផ្សាយពត៌មាន និងអត្ថាធិប្បាយ លុះណាតែការប្រើសិទ្ធិនេះមិនប៉ះពាល់ កិត្តិយសបុគ្គល សន្តិសុខជាតិ និង ទំនៀមទម្លាប់ល្អ ។

ត្រូវចាត់ទុកជាកិត្តិយសបុគ្គល គឺ កិត្តិយសដែលទាក់ទងនិងសេចក្ដីថ្លៃថ្នូរ ហើយនឹងជីវភាពឯកជននៃបុគ្គល ។

**មាត្រា ២២ –**

សារពត៌មានអាចធ្វើអត្ថាធិប្បាយ ឬ រិះគន់ដោយសេរី នូវនយោបាយ ឬ កម្មវិធីការងារនៃរដ្ឋាភិបាល ។ ក៏ប៉ុន្តែ ការរិះគន់ដោយជេរប្រមាថចំពោះកិច្ចការរដ្ឋាភិបាល ត្រូវហាមឃាត់ ។ ការរិះគន់ដែលឥតមានការជេរប្រមាថ តែក្នុងបំណងអាក្រក់ ឬ ប្រឆាំង ដែលអាចជំទាស់មិនឱ្យសកម្មភាពនៃរដ្ឋាភិបាល រដ្ឋការ ឬ តុលាការ ប្រព្រឹត្តទៅបាន ក៏ត្រូវហាមឃាត់ដែរ ។

មាត្រា ២៣ –

គ្មានសារពត៌មានណាមួយ អាចទទួលការចោទប្រកាន់បាន កាលបើសារពត៌មាននោះ បានរាយការណ៏ ឬ ផ្សាយដោយត្រឹមត្រូវ និង ដោយសុទ្ធចិត្ត អំពី :

- កិច្ចពិភាក្សាជាសាធារណៈនៃសភាទាំងពីរ ឬ គណៈកម្មការនៃសភា និង ការពិភាក្សានៅសាលាជំនុំជំរះក្តី
- សេចក្តីថ្លែងការណ៏របស់សមាជិកនៃរដ្ឋសភា និងព្រឹទ្ធសភា ឬ សមាជិករដ្ឋាភិបាល អំពីយោបល់ខាងនយោបាយ ,
- ឯកសារទាំងឡាយដែលគ្មានលក្ខណៈជាអាថ៌កំបាំង ឬ ជាការសម្ងាត់ ដែលបែកផ្សាយដោយសភាទាំងពីរ ឬ រដ្ឋាភិបាល ។

មាត្រា ២៤ –

គ្មានសារពត៌មានណាមួយ អាចទទួលការចោទប្រកាន់បាន ដោយហេតុមកអំពីបានចុះផ្សាយនូវសេចក្តីដកស្រង់ ឬ សេចក្តីបកប្រែចេញពីអត្ថបទនៃសារពត៌មាន ឬ ទស្សនាវដ្តីបរទេស ដែលទទួលការអនុញ្ញាតឲ្យផ្សាយនៅសាធារណរដ្ឋខ្មែរ ប្រសិនបើសេចក្តីបកប្រែ ឬ សេចក្តីដកស្រង់ទាំងនោះ ដែលបានធ្វើឡើង ដោយត្រឹមត្រូវនិងដោយសុទ្ធចិត្ត ។

ត្រូវហាមឃាត់ចំពោះសារពត៌មាន មិនឲ្យចុះផ្សាយនូវអត្ថបទជាលាយលក្ខណ៏អក្សរណា ដែលត្រូវបានហាមឃាត់រួចមក

ហើយ ទោះជាក្រោមចំណងជើងខុសគ្នាពីអត្ថបទដើមក៏ដោយ។ នឹងត្រូវហាមឃាត់ដូចគ្នា ចំពោះឯកសារខាងរដ្ឋបាល ឯកសារខាងទូត ឬ ឯកសារដែលទាក់ទងទៅនឹងកិច្ចការពារជាតិ ដែលហាមឃាត់មិនឱ្យចុះផ្សាយ ។

មាត្រា ២៥ –

ត្រូវហាមឃាត់មិនឱ្យផ្សាយនូវអត្ថបទ រូបថត រូបភាព គំនូរ ផ្ទាំងផ្សាយ រូបចម្លាក់ រូបគំនូរផាត់ពណ៌ ឬ ការនិពន្ធអាសអាភាស ដែលប៉ះពាល់ដល់ទំនៀមទម្លាប់ល្អ ។

មាត្រា ២៦ –

ត្រូវហាមឃាត់មិនឱ្យផ្សាយនូវអត្ថបទ ឬ វិចិត្ររូបស្ដីពីបុគ្គលិកលក្ខណៈនៃអនីតិជន អាយុតិចជាង ១៨ ឆ្នាំ ដែលបានចាកចេញពីមាតាបិតា អាណាព្យាបាលរបស់ខ្លួន ឬពីបុគ្គល ឬស្ថាប័ន ដែលទទួលភារៈគ្រប់គ្រងអនីតិជនទាំងនោះ។ក៏ប៉ុន្តែការផ្សាយនេះ មិនអាចចូលជាបទល្មើស ប្រសិនបើការផ្សាយនោះធ្វើឡើងដោយមានពាក្យសុំជាលាយលក្ខណ៍អក្សរពីបុគ្គលដែលទទួលភារៈថែរក្សាអនីតិជន ឬ តាមសេចក្ដីស្នើសុំ ឬ ដោយមានសេចក្ដីអនុញ្ញាតជា លាយលក្ខណ៍អក្សរពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពីអភិបាលខេត្ត ឬ ក្រុង ពីរដ្ឋអាជ្ញា ឬ ពីសុភាចារបុរស ។

មាត្រា ២៧-

ទិនានុប្បវត្តិ ឬ ទស្សនាវដ្តីទាំងឡាយមិនត្រូវផ្សាយអត្ថបទដែលមានលក្ខណៈ :

ក- ញុះញង់មនុស្សដទៃ ឱ្យប្រព្រឹត្តអំពើចោរកម្ម ការបង្ហិចបំផ្លាញ មនុស្សឃាត ការធ្វើឱ្យមានរបួសស្លាកស្នាម និង អគ្យន្តរាយ ។

ខ- ញុះញង់ឱ្យអ្នកដទៃធ្វើឱ្យប៉ះពាល់សន្តិសុខផ្ទៃក្នុង ឬ ក្រៅប្រទេស ។

គ- ញុះញង់មិនឱ្យទាហានគោរពវិន័យ ។

ការញុះញង់ អាចចេញពីការញុះញង់ដោយចំពោះ ឬ មិនចំពោះ ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិមខាងលើនេះ ពិសេស គឺ ការពោលសរសើរ ឬ ការជួយដោះស្រាយដើម្បីគាំទ្រអំពើទាំងនោះ ជាគុណប្រយោជន៍ដល់ជនទាំងឡាយដែលបានប្រព្រឹត្ត ឬ បានប៉ងប្រព្រឹត្តនូវបទឧក្រិដ្ឋ និង បទមជ្ឈិមទាំងនេះ ។

សម្ភារៈទាំងឡាយដែលជាភស្តុតាងនៃការប្រព្រឹត្តិបទល្មើស និង ត្រូវរឹបអូស ពិសេស គឺម៉ាស៊ីនផ្តិតអក្សរ សំណៅដើម និង ម៉ាស៊ីនបោះពុម្ព ។

មាត្រា ២៨-

ត្រូវហាមឃាត់ចំពោះសារពត៌មាន មិនឱ្យផ្សាយពត៌មានខុស ឬ ពត៌មានក្លែងក្លាយ ឬ បំផ្លើសដោយចេតនាក្នុងគោលបំណងណាមួយ ដូចខាងក្រោមនេះ :

- ធ្វើឲ្យមានការភ័យភ្ញាក់ផ្អើលក្នុងបណ្ដាប្រជាពលរដ្ឋ ឬ បណ្ដាលឲ្យខូចរបៀបរៀបរយសាធារណៈ ។

- ធ្វើឲ្យរំជើបរំជួលដោយចំពោះ ឬ មិនចំពោះ ដល់ទំនុកទុកចិត្តនៃសាធារណជន អំពីភាពរឹងប៉ឹងនៃប្រាក់រៀល អំពីតម្លៃមូលនិធិ គ្រប់បែបយ៉ាងរបស់រដ្ឋ ។

- ធ្វើឲ្យខូចវិន័យនិងទឹកចិត្តប្រយុទ្ធរបស់កងទ័ព ។

- ធ្វើការបំផ្លាញបំបែក ដោយសាររឿងសាសនា និង រឿងជាតិសាសន៍ ។

- ញុះញង់ឲ្យកើតសង្គ្រាមស៊ីវិល ដោយជំរុញបណ្ដាជនឲ្យកាន់អាវុធប្រឆាំងគ្នាឯង ។

<u>មាត្រា ២៥</u> –

ត្រូវហាមឃាត់ចំពោះសារពត៌មាន មិនឲ្យធ្វើការវិទ្ធង្សនា ក្នុងភាសាណាមួយក្ដី ឬ ក្នុងទម្រង់ការណាមួយក្ដី ក្នុងគោលបំណងពិតប្រាកដ ដូចខាងក្រោម :

ក - ឬមួយបញ្ជាក់ ពន្យល់ ឬ បញ្ចុះបញ្ចូលឲ្យគេជឿថាជាការត្រឹមត្រូវតាមច្បាប់ ថាជាការចាំបាច់ឬជាការគប្បី ត្រូវផ្លាស់ប្ដូររដ្ឋធម្មនុញ្ញសាធារណរដ្ឋ របៀបរៀបចំអំណាចសាធារណៈទាំងឡាយ ច្បាប់ ឬ បទបញ្ញាទាំងឡាយខាងរដ្ឋបាល ដោយប្រើមធ្យោបាយណាមួយ ក្រៅពីមធ្យោបាយដែលរដ្ឋធម្មនុញ្ញ ឬ ច្បាប់អនុញ្ញាតឲ្យធ្វើ ។

ខ - ឬមួយការពារ ពន្យល់ ឬ បញ្ចុះបញ្ចូលឲ្យគេ

ជឿថាជាការត្រឹមត្រូវតាមច្បាប់ ថាជាការចាំបាច់ ឬ ជាការគប្បី ត្រូវធ្វើការសើរើរដ្ឋធម្មនុញ្ញត្រង់ចំណុចដែលរដ្ឋធម្មនុញ្ញនេះហាមមិនឱ្យមានការសើរើ ទោះជាដោយមធ្យោបាយណា ដែលមានភាពត្រឹមត្រូវតែសំបកក្រៅក្តី ។

គ - ឬមួយព្យាយាមចង់ឱ្យមានការប្រមាថ ឬ គំនុំគុំគួន ចំពោះរដ្ឋាភិបាលខ្មែរ ឬ ប្រទេសជាសម្ពន្ធមិត្តឬជាមិត្តណាមួយៗ ក៏ប៉ុន្តែ ការចោទប្រកាន់នឹងពុំអាចចាប់ធ្វើទៀងដោយអនុវត្ត វាក្យខ័ណ្ឌ "គ" នេះបានទេ បើគ្មានពាក្យបណ្តឹងជាមុនអំពីសាមីរដ្ឋាភិបាល ។

ឃ - ឬមួយព្យាយាមចង់ឱ្យមានគំនុំគុំគួន ឬ ការប្រមាថ រវាងប្រជាពលរដ្ឋនិងអំណាចសាធារណៈ ឬ រវាងវណ្ណៈ ក្រុម ឬ ប្រភេទពលរដ្ឋទីទៃ ៗ ពីគ្នា ឬ រវាងភូមិភាគមួយនៃសាធារណរដ្ឋខ្មែរ និង ភូមិភាគមួយទៀត រវាងសាសនាមួយនឹងសាសនាមួយទៀត ដែលរដ្ឋាភិបាលទទួលស្គាល់ ។

ង - ឬមួយព្យាយាមចង់ឱ្យមានការមិនគោរព ទោះបីជាអកម្មក្តី នូវច្បាប់ទាំងឡាយ បទបញ្ជាទាំងឡាយឬបញ្ជាត្រឹមត្រូវតាមច្បាប់នៃអាជ្ញាធររដ្ឋបាល ឬ តុលាការដែលប្រកបដោយលក្ខណៈច្បាប់ ។ប្រសិនបើ ការព្យាយាមចង់បង្កើតជាឧទ្ទាមកម្ម ដោយមានហេតុបច្ច័យកើតឡើង ទណ្ឌកម្មនឹងត្រូវធ្ងន់ថែមទៀត ដោយក្នុងករណីនេះ ត្រូវអនុវត្តបទបញ្ញត្តិទាំងឡាយ ទាក់ទងទៅនឹងឧទ្ទាមកម្មប្រឆាំងនឹងអំណាចរដ្ឋ ។

មាត្រា ៣០ –

ត្រូវហាមឃាត់ចំពោះសារពត៌មាននិងទស្សនាវដ្តី ទាំងឡាយមិនឲ្យទទួលដោយចំពោះក្តី មិនចំពោះក្តី នូវមូលនិធិ ពីបរទេស សំរាប់ធ្វើការឃោសនានយោបាយ ទោះជាក្នុងទម្រង់ណាមួយក៏ដោយនិងក្នុងឋានៈជាអ្វីក៏ដោយ៕

អ្វី ៗ ជាមធ្យោបាយ ដែលប្រើក្នុងការប្រព្រឹត្តិបទល្មើសនេះ នឹងត្រូវរឹបអូស សាលក្រមនឹងត្រូវបញ្ជាតាមករណីនីមួយ ៗ ឲ្យរឹបអូស បំបាត់ចោល ឬ បំផ្លាញចោល នូវមធ្យោបាយ ដែលប្រើក្នុងបទល្មើសនេះ ៕

មាត្រា ៣១ –

ត្រូវហាមឃាត់មិនឲ្យប្រើសារពត៌មាន ដើម្បីប្រមាថមើលងាយ :

ក - ប្រធានាធិបតីនៃសាធារណរដ្ឋ អនុប្រធានាធិបតីនៃសាធារណរដ្ឋ ព្រះសង្ឃនាយក និង ព្រះសង្ឃទាំងឡាយ ទាំងពីរនិកាយ ,

ខ - ប្រមុខរដ្ឋ ឯកអគ្គរដ្ឋទូត អ្នកទទួលបេសកកម្មទូត ឬ កុងស៊ុលនៃប្រទេសនានា ដែលមានការប្រស្រ័យទាក់ទងខាងការទូត ជាមួយសាធារណរដ្ឋខ្មែរ ៕

គ - អ្នកតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋាភិបាល សមាជិកតុលាការកំពូល ឧត្តមក្រុមប្រឹក្សាតុលាការ តុលាការធម្មនុញ្ញ តុលាការជាន់ខ្ពស់ និងអង្គការរដ្ឋឯទៀត

ភ្នាក់ងារនៃក្រសួងរដ្ឋបាល សមាជិកកងទ័ព ឬ ប្រជាពលរដ្ឋ ដែលទទួលភារៈជាបណ្តោះអាសន្ន ឬ ជាធម្មតា នូវអាណត្តិរដ្ឋបាល ឬ អាណត្តិជ្រើសតាំង ចំពោះសកម្មភាពទាំងឡាយ ដែលទាក់ទងនឹងបេសកកម្ម ឬ មុខងាររបស់សាមីជន ។

ឃ- បុគ្គលឯកជនទាំងឡាយ ទោះបីជាជនសាមញ្ញ ឬ ជាអង្គការដែលច្បាប់ទទួលស្គាល់ ។

ង- មនុស្សដែលស្លាប់ទៅហើយ ក្នុងគោលបំណងធ្វើឱ្យប៉ះពាល់កិត្តិយស និង កិត្យានុភាព នៃអ្នកទទួលមត៌ក ប្តី ឬ ប្រពន្ធ ឬ អនីតិជន ដែលនៅរស់ ។

ដែលហៅថា ការប្រមាថមើលងាយ គឺការប្រើពាក្យពេចន៍ទាំងឡាយណាដែលមានលក្ខណៈប្រមាថមើលងាយ បន្ទាប បន្ថោក ឬ ជេរប្រទេច ។

មាត្រា ៣២-
---------

ត្រូវហាមឃាត់មិនឱ្យប្រើសារពត៌មាន ដើម្បីបរិហារកេរ្តិ៍ ជាសាធារណៈ ចំពោះ :

ក- ប្រធានាធិបតីនៃសាធារណរដ្ឋ អនុប្រធានាធិបតីនៃសាធារណរដ្ឋ ព្រះសង្ឃនាយក និង ព្រះសង្ឃទាំងពីរ និកាយ ,

១- ប្រមុខរដ្ឋ ឯកអគ្គរដ្ឋទូត អ្នកទទួលបេសកកម្មទូត ឬ កុងស៊ុលនៃប្រទេសនានា ដែលមានការប្រស្រ័យទាក់ទងខាងការទូតជាមួយសាធារណរដ្ឋខ្មែរ

គ - អង្គការនីតិបញ្ញត្តិ នីតិប្រតិបត្តិ និង តុលាការ អង្គការនានា ដែលជ្រើសតាំងឡើងដោយប្រជារាស្ត្រ និង អង្គការទាំងឡាយណា ដែលតែងតាំងឡើងតាមផ្លូវច្បាប់ ។

ឃ - អ្នកតំណាងរាស្ត្រ ព្រឹទ្ធសភា សមាជិករដ្ឋាភិបាល សមាជិកតុលាការកំពូល ឧត្តមក្រុមប្រឹក្សាតុលាការ តុលាការធម្មនុញ្ញ តុលាការជាន់ខ្ពស់ និង អង្គការរដ្ឋឯទៀត ភ្នាក់ងារនៃក្រសួងរដ្ឋបាលនានា សមាជិកកងទ័ព ឬ ប្រជាពលរដ្ឋដែលទទួលភារៈជាបណ្ដោះអាសន្ន ឬ ជាធម្មតានូវអាណត្តិរដ្ឋបាល ឬ អាណត្តិជ្រើសតាំង ចំពោះសកម្មភាពទាំងឡាយដែលទាក់ទងនិង របសកកម្ម ឬ មុខងាររបស់សាមីជន ។

ង - បុគ្គលឯកជន ទោះបីជាជនសាមញ្ញ ឬ អង្គការដែលច្បាប់ទទួលស្គាល់ ។

ច - មនុស្សដែលស្លាប់ទៅហើយ ក្នុងគោលបំណងធ្វើឱ្យប៉ះពាល់កិត្តិយស និង កិត្យានុភាពនៃអ្នកទទួលមត៌ក ប្តី ឬ ប្រពន្ធ ឬ អនីតិជនដែលនៅរស់ ។

មាត្រា ៣៣.-

ត្រូវចាត់ទុកជាការបរិហារកេរ្តិ៍ គឺការអះអាងទាំងឡាយណា ឬ ការដាក់កំហុស ពីហេតុការណ៍ណាមួយ ដែលប៉ះពាល់កិត្តិយស ឬ កិត្យានុភាពរបស់បុគ្គល , អង្គការ ឬ ក្រុមណាមួយ ។

ការបង្ហាញឱ្យឃើញភាពពិតប្រាកដ អំពីហេតុការណ៍

ដែលនាំមានការបរិហារកេរ្តិ៍ អាចធ្វើទៅបានលើកលែងតែ :

ក - កាលណាជាក់កំហុសនោះទាក់ទងនឹងជីវភាពឯកជនរបស់បុគ្គល ។

ខ - កាលណាជាក់កំហុសនោះ ទាក់ទងទៅនឹងហេតុការណ៍ទាំងឡាយណា ដែលកន្លងមកជាង ១០ ឆ្នាំហើយ ។

គ - កាលណាជាក់កំហុសនោះ ទាក់ទងទៅនឹងហេតុការណ៍ណាមួយដែលជាបទល្មើស ត្រូវបានទទួលការលើកទោសរួចមកហើយ ឬ បទល្មើសរលត់ទៅហើយ ឬ ក៏ហេតុការណ៍ដែលត្រូវបានរលាយទៅវិញ ដោយបាននីតិសម្បទា ដែលច្បាប់ទទួលស្គាល់ថា មានសិទ្ធិដូចដើមវិញ ឬ ដោយការសើរើនៃតុលាការ។

ក្នុងករណីណាដែលហេតុការណ៍ ដែលត្រូវចាត់ទុកជាការបរិហារកេរ្តិ៍នោះ មានភស្តុតាងឱ្យឃើញថា ពិតមែន ជនជាប់ចោទនឹងត្រូវបានរួចខ្លួន ។

មាត្រា ៣៥ -

សារពត៌មានមិនត្រូវផ្សាយពាក្យចោទប្រកាន់ ឬ សំណុំលិខិតនានា ដែលទាក់ទងរឿងរ៉ាវជាបទឧក្រិដ្ឋ មុនពេលកាត់សេចក្តីជាសាធារណៈនៃតុលាការឡើយ លើកលែងតែការផ្សាយនោះ បានធ្វើឡើងតាមពាក្យសុំជាលាយលក្ខណ៍អក្សរពីរដ្ឋអាជ្ញា ។

ចាប់តាំងពីពេលសួរចម្លើយ រហូតដល់ពេលជំនុំជំរះជាចំណាត់នៃតុលាការ សារពត៌មានមិនត្រូវផ្សាយពត៌មាន

ឬ សេចក្តីអត្ថាធិប្បាយណា ដែលអាចមានឥទ្ធិពលទៅលើលក្ខណៈសុចរិតនៃការកាត់សេចក្តី ។

សារពត៌មានមិនត្រូវផ្សាយសេចក្តីរាយការណ៍ អំពីអធិករណ៍ ស្តីពីការបរិហារកេរ្តិ៍នៅក្នុងករណីដែលបានព្រាងទុកនៅកថាខ័ណ្ឌ ក-ខ-គ នៃមាត្រា ៣២ និងមិនត្រូវផ្សាយការពិភាក្សារបស់តុលាការ ស្តីពីការរកបិតុភាព ការផ្តាច់សមគ្គសង្វាស និង ការរៀបការសង្វាស ព្រមទាំងរឿងក្តី ស្តីអំពីការរំលូតកូន ។ការហាមឃាត់ទាំងនេះ ពុំទាក់ទងទៅនឹងសាលក្រមតុលាការ ដែលអាចផ្សាយបានជានិច្ចនោះទេឡើយ ។

នៅគ្រប់រឿងរដ្ឋប្បវេណីទាំងអស់ សាលាជំនុំជំរះក្តីអាចហាមឃាត់មិនឱ្យផ្សាយនូវសេចក្តីរាយការណ៍ ស្តីពីការជំនុំជំរះបាន ។

ត្រូវហាមឃាត់មិនឱ្យផ្សាយសេចក្តីរាយការណ៍ ស្តីពីការជំនុំសម្ងាត់ នៅក្នុងបន្ទប់របស់គណៈប្រឹក្សាខាងតុលាការ ឬនៅគ្រប់សាលាជំនុំជំរះក្តី ។

មាត្រា ៣៥ -

សារពត៌មានមិនត្រូវផ្សាយមុនការកាត់សេចក្តី

ដាច់ណាត់ នូវអត្ថាធិប្បាយទាំងឡាយ ដែលមានគោលបំណងធ្វើការបង្ខិតបង្ខំទៅលើសេចក្តីថ្លែងការណ៍នៃសាក្សីទាំងឡាយ ឬ ទៅលើសេចក្តីសំរេចនៃសាលាក្តី ខាងសួរចម្លើយ ឬ សាលាជំនុំជំរះក្តី ។

កំប៉ុន្តែ បទបញ្ញានេះ ពុំត្រូវអនុវត្តទៅលើអញ្ញាធិ-
ប្បាយខាងរឿងបច្ចេកទេស សុទ្ធសាធ ទៅលើអំពើ វាចា
និង លិខិតលាយលក្ខណ៍អក្សរទាំងឡាយ ដែលមានគោលបំណង
សុំសេចក្តីទណ្ឌកម្មណាមួយ ។

មាត្រា ៣៦ —

ចាងហ្វាងនៃការផ្សាយ ត្រូវចុះផ្សាយឥតគិតថ្លៃ
ក្នុងទំព័រដើមនៃលេខក្រោយនៃសារពត៌មាន ឬ ទស្សនាវដ្តី
នូវសេចក្តីបដិសេធ ឬ សេចក្តីកែតម្រូវទាំងឡាយដែលផ្ញើមក
ចំពោះខ្លួនពី សំណាក់អាជ្ញាធរសាធារណៈខាងស៊ីវិល ឬទាហាន
ចំពោះអំពើទាំងឡាយក្នុងមុខតំណែងរបស់ខ្លួន ដែលសារពត៌មាន
ឬ ទស្សនាវដ្តីនោះបានចុះផ្សាយខុសពីការពិត ។ តែប៉ុន្តែ
សេចក្តីបដិសេធ ឬ សេចក្តីកែតម្រូវទាំងនោះ មិនត្រូវលើសពី
ពីរដងនៃអត្ថបទដែលសេចក្តីបដិសេធឬសេចក្តីកែតម្រូវនោះ
ឆ្លើយតបទៅនឹងអត្ថបទសារពត៌មាន ឬ ទស្សនាវដ្តីនោះ។

មាត្រា ៣៧ —

ចាងហ្វាងនៃការផ្សាយ ត្រូវចុះផ្សាយក្នុងរយៈពេល
៣ ថ្ងៃ ដែលទទួល ឬ ក្នុងលេខក្រោយបន្ទាប់ ចំពោះទស្សនា
វដ្តី នូវសេចក្តីឆ្លើយតប ឬ សេចក្តីកែតម្រូវរបស់បុគ្គល ឬ ក្រុម
ហ៊ុន ដែលមានឈ្មោះ ឬ ចង្អុលបង្ហាញក្នុងសារពត៌មាន ឬ
ទស្សនាវដ្តី ។

ការចុះផ្សាយនេះ ត្រូវធ្វើឡើងនៅត្រង់កន្លែងដដែល និងដោយប្រើអក្សរដដែល ដូចដែលអត្ថបទនោះបានលើកយកមកនិយាយ ។ ការចុះផ្សាយនេះ ត្រូវធ្វើឡើងដោយឥតគិតថ្លៃ ប្រសិនបើសេចក្ដីឆ្លើយតប ឬ សេចក្ដីកែតម្រូវមិនលើសពីពីរដងនៃប្រវែងអត្ថបទដើមនៃសារព័ត៌មាននោះ ។ ប្រសិនបើសេចក្ដីឆ្លើយតប ឬ សេចក្ដីកែតម្រូវនោះលើសពីពីរដងនៃប្រវែងអត្ថបទនោះ តម្លៃចុះផ្សាយត្រូវគិតតែទៅលើប្រវែងអត្ថបទដែលលើសនោះប៉ុណ្ណោះ ។ តម្លៃចុះផ្សាយនេះ ត្រូវគិតតាមតម្លៃនៃការផ្សាយពាណិជ្ជកម្ម ។

មាត្រា ៣៨ –

ប្រសិនបើ ការផ្សាយនៃសេចក្ដីឆ្លើយតប ឬ សេចក្ដីកែតម្រូវ មិនបានធ្វើឡើងក្នុងរយៈពេល ឬ ក្នុងទម្រង់លក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ៣៦ និង ៣៧ ទេ ចាងហ្វាងនៃការផ្សាយ ត្រូវទទួលពិន័យជាប្រាក់ចំនួនពីប្រាំពាន់ "៥.០០០" ទៅមួយម៉ឺន "១០.០០០ រៀល" ដោយពុំទាន់គិតពីជម្ងឺចិត្ត ដែលដើមចោទអាចទាមទារ ។

ប្រសិនបើ ចាងហ្វាងនៃការផ្សាយ ពុំព្រមចុះផ្សាយនូវសេចក្ដីឆ្លើយតប ឬ សេចក្ដីកែតម្រូវទេ នោះចាងហ្វាងនៃការផ្សាយ និងត្រូវទទួលទោសគុក ពីប្រាំមួយ "៦" ថ្ងៃទៅមួយ "១" ខែ ហើយនឹងត្រូវពិន័យជាប្រាក់ពីប្រាំពីរពាន់ "៧.០០០" ទៅដប់ប្រាំពាន់ "១៥.០០០" រៀល ឬ មួយត្រូវទទួលទណ្ឌកម្ម

មួយ ក្នុងចំណោមទណ្ឌកម្មទាំងពីរនេះ ដោយពុំទាន់គិតដល់ជម្ងឺចិត្ត ដែលដើមចោទអាចទាមទារ ។

តុលាការត្រូវវិនិច្ឆ័យក្នុងរយៈពេល ១០ ថ្ងៃ គិតចាប់តាំងពីពេលបានទទួលពាក្យបណ្ដឹង ។ ក្រៅពីទណ្ឌកម្មនិងជម្ងឺចិត្ត សាលក្រមត្រូវមានដាក់បញ្ជាឲ្យចុះផ្សាយជាបន្ទាន់តាមសារព័ត៌មាន នូវសេចក្ដីឆ្លើយតប ឬ សេចក្ដីកែតម្រូវនោះ ទោះបីជាមានការប្ដឹងជំទាស់ ឬ ប្ដឹងឧទ្ធរណ៍ក៏ដោយ ។ ប្រសិនបើ មានការប្ដឹងឧទ្ធរណ៍ តុលាការត្រូវវិនិច្ឆ័យក្នុងរយៈពេល ១០ ថ្ងៃ ចាប់ពីបានទទួលពាក្យបណ្ដឹង នៅមន្ទីរក្រឡាបញ្ជី ។

មាត្រា ៣៨ –

ក្នុងកំឡុងពេលបោះឆ្នោត រយៈពេលកំណត់ក្នុងមាត្រា ៣៧ ចំពោះទិនានុប្បវត្តិ និង បង្រួញមកត្រឹមតែ ២៤ម៉ោង។ សេចក្ដីឆ្លើយតប ឬ សេចក្ដីកែតម្រូវ ត្រូវផ្ញើទៅសារព័ត៌មាន ឲ្យបានយ៉ាងហោចណាស់ប្រាំមួយម៉ោងមុនពេលដែលសារព័ត៌មានត្រូវយកមកតំកល់ទុកតាមផ្លូវច្បាប់ ដូចមានចែងក្នុងមាត្រា១៦ រីឯកាលបរិច្ឆេទព្រាងទុក សំរាប់ការជំនុំជំរះនៃតុលាការវិញ ត្រូវកំណត់ពេលម្ភៃបួនម៉ោង ក្រោយដើមចោទបានដាក់ពាក្យបណ្ដឹង ។

## ជំពូក ៥

## អំពីការចែកសារពត៌មាន ឬទស្សនាវដ្តីទាំងឡាយ

**មាត្រា ៤០ –**

បុគ្គល ឬ ក្រុមហ៊ុនទាំងអស់ ដែលទទួលភារៈចែកសារពត៌មាន ឬ ទស្សនាវដ្តី ដែលខ្លួនផ្សាយដោយខ្លួនឯង ត្រូវធ្វើពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅក្រសួងឃោសនាការ ។

ពាក្យបណ្តឹងនេះ ត្រូវបញ្ជាក់ឈ្មោះអង្គការ ជាអ្នកចែក ត្រូវបញ្ជីរាយនាមបុគ្គលិក ដែលទទួលភារៈចែក ត្រូវបញ្ជីនិងអាសយដ្ឋានរបស់ភ្នាក់ងារអ្នកចែក នៅតាមភូមិភាគ ឬ តាមខេត្ត នានា ។

**មាត្រា ៤១ –**

ភ្នាក់ងារអ្នកចែកទាំងអស់ ដែលចង់ធ្វើការចែកសារពត៌មាន ឬ ទស្សនាវដ្តីទាំងឡាយ របស់អ្នកបោះពុម្ពផ្សាយណាមួយផ្សេងទៀត ត្រូវបង់ប្រាក់ធានាចំនួន៥០,០០០រ ទៅអគ្គរតនាគារ ក្រៅពីលក្ខខ័ណ្ឌទាំងឡាយ ដែលមានចែងក្នុងមាត្រា ៤០ ។ សេចក្តីចម្លងបង្កាន់ដៃដែលបង់ប្រាក់ធានានេះ ត្រូវតែផ្ញើទៅក្រសួងមហាផ្ទៃនិងក្រសួងឃោសនាការ ក្នុងរយៈពេល ១០ ថ្ងៃ មុនការប្រកបអាជីវកម្មរបស់ខ្លួន ។

ប្រសិនបើភ្នាក់ងារចែកបានប្រព្រឹត្តល្មើសនឹងមាត្រា

នេះនឹងត្រូវហាមឃាត់មិនឲ្យប្រកបអាជីវកម្មរបស់ខ្លួន ហើយនឹងត្រូវទទួលទណ្ឌកម្មតាមមាត្រា ៥៦ ។

ត្រូវចាត់ទុកជាភ្នាក់ងារអ្នកចែក គឺអគ្គរការីទាំងអស់ដែលមានសិទ្ធិផ្តាច់មុខនៃការចែកសារពត៌មាន ឬទស្សនាវដ្តីណាមួយ ក្នុងដែនដីសាធារណរដ្ឋខ្មែរ ។

មាត្រា ៥២ –

ការចែក ឬ ការដាក់លក់ សារពត៌មាន ឬ ទស្សនាវដ្តីទាំងឡាយមកពីបរទេស ហើយបោះពុម្ពនៅបរទេស ត្រូវមានសេចក្តីអនុញ្ញាតផ្សាយប្រកាសនៃរដ្ឋមន្ត្រីក្រសួងឃោសនាការ ។

ត្រូវទទួលទណ្ឌកម្មដូចគ្នាខាងលើនេះ ភ្នាក់ងារអ្នកចែកទាំងអស់ ដែលបានចែកដោយចេតនានូវសារពត៌មាន ឬ ទស្សនាវដ្តីទាំងឡាយដែលមានលក្ខណៈជាបទមជ្ឈិម ។

o

o o

## ជំពូក ៦

## អំពីការផ្អាក ការរឹបអូសតាមផ្លូវរដ្ឋបាលនិងទណ្ឌកម្ម

មាត្រា ៥៣ –

ការផ្អាកជាស្ថាពរនៃសារពត៌មាន ឬ ទស្សនាវដ្តីណាមួយ និងអាចសំរេចបាន លុះណាតែមានសាលក្រមចេញពី

តុលាការមានសមត្ថកិច្ច ។

មាត្រា ៥៥ –

ដើម្បីការពារសន្តិសុខជាតិ របៀបរៀបរយ សាធារណៈ ព្រមទាំងទំនៀមទំលាប់ល្អ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងឃោសនាការ អាចបញ្ជាឲ្យរឹបអូសតាមផ្លូវរដ្ឋបាល នូវសារពត៌មានឬទស្សនាវដ្ដីណាមួយមុនពេល ឬ ក្នុងពេលចែកផ្សាយ ។

ក្នុងករណីប្រព្រឹត្តបទល្មើសសាជាថ្មី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងឃោសនាការ អាចបញ្ជាឲ្យផ្អាកការផ្សាយជាបណ្ដោះអាសន្ននៃសារពត៌មានឬទស្សនាវដ្ដីនោះ ។ ក៏ប៉ុន្តែ ក្នុងរយៈពេល ៧ ថ្ងៃ ក្រោយពីការរឹបអូសនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងឃោសនាការ ត្រូវប្ដឹងចោទប្រកាន់ទៅតុលាការមានសមត្ថកិច្ច។

ក្នុងករណីដែលតុលាការនឹងប្រកាសឲ្យរួចខ្លួនដល់ចាងហ្វាងការផ្សាយនៃសារពត៌មាន ឬ ទស្សនាវដ្ដីនោះ ចាងហ្វាងនៃការផ្សាយនឹងអាចទាមទារភ្លាមក្នុងពេលជំនុំជំរះក្ដីឲ្យសងជម្ងឺចិត្តតាមតម្លៃនៃការខូចខាតដែលខ្លួនបានទទួល ។

ក្នុងករណីនៃការកាត់ទោសឲ្យសងជម្ងឺចិត្ត ការសងជម្ងឺចិត្តនេះ នឹងត្រូវនៅក្នុងបន្ទុករដ្ឋ ។

មាត្រា ៤៥-

ការប្រព្រឹត្តិល្មើសនឹងមាត្រា ៧ វាក្យខ័ណ្ឌ " ៣ " ឬ នឹងមាត្រាមួយក្នុងចំណោមមាត្រា ១៥-១៦-១៧ និង ៤០ នឹងត្រូវពិន័យជាប្រាក់ចំនួន ពី ១.៥០០ ដល់ ១៥.០០០ រៀល។

មាត្រា ៤៦-

ការប្រព្រឹត្តិល្មើសនឹងមាត្រាមួយ ក្នុងចំណោមមាត្រា ១០-៣១- កថាខ័ណ្ឌ "គ-ឃ-ង" ហើយនឹងមាត្រា ២៥-២៦-៤១ និង ៤២ នឹងត្រូវទោសគុកពីប្រាំមួយថ្ងៃ ដល់ពីរខែ ឬមួយត្រូវពិន័យជាប្រាក់ចំនួនពី ៣.០០០ រៀល ដល់ ៣០.០០០ រៀល ឬមួយត្រូវទោសគុកផង ត្រូវពិន័យជាប្រាក់ថែមទៀតផង ។

មាត្រា ៤៧

ការប្រព្រឹត្តិល្មើសនឹងមាត្រា ២២-២៤ និងមាត្រា ៣១ កថាខ័ណ្ឌ "ខ" និងមាត្រា ៣២ កថាខ័ណ្ឌ "គ-ឃ-ង-ច" ហើយនឹងមាត្រា ៣៤ នឹងត្រូវទោសគុកពី ១៥ ថ្ងៃ ដល់បីខែ ឬមួយត្រូវពិន័យជាប្រាក់ចំនួនពី ១០.០០០ រៀល ដល់១០០.០០០ រៀល ឬមួយត្រូវទោសគុកផង ត្រូវពិន័យជាប្រាក់ថែមទៀតផង ។

មាត្រា ៤៨-

ការប្រព្រឹត្តិល្មើសនឹងមាត្រាមួយ ក្នុងចំណោមមាត្រា ៨-១៨-១៩-២៧-៣១ កថាខ័ណ្ឌ "ក" មាត្រា ៣២ កថាខ័ណ្ឌ "ខ" ហើយនឹងមាត្រា ៧១ និងត្រូវទោសគុកពីបីខែដល់ប្រាំ

មួយខែ ឬមួយត្រូវពិន័យជាប្រាក់ចំនួនពី ៣០.០០០រៀល ដល់ ៣០០.០០០រៀល ឬមួយត្រូវទោសគុកផង ត្រូវពិន័យជាប្រាក់ថែមទៀតផង ។

មាត្រា ៤៩-

ការប្រព្រឹត្តល្មើសនឹងមាត្រា ២៨-២៩-៣០ និង៣២ កថាខ័ណ្ឌ "ក" និងត្រូវទោសគុកពីប្រាំមួយខែ ដល់មួយឆ្នាំ ឬមួយត្រូវពិន័យជាប្រាក់ចំនួនពី៥០.០០០រៀលដល់៤០០.០០០រៀល ឬ មួយត្រូវទោសគុកផង ត្រូវពិន័យជាប្រាក់ថែមទៀតផង។

មាត្រា ៥០

ក្នុងករណីដែលតុលាការកាត់សេចក្ដីពីបទមជ្ឈិម ដូចមានចែងក្នុងមាត្រា ២៧-២៨-២៩ និង ៣០ តុលាការត្រូវតែកាត់សេចក្ដីបញ្ជាឱ្យផ្អាកការផ្សាយជាស្ថាពរនៃសារពត៌មាន ដែលជាប់ចោទ ។

០ ០

០

## ចំពូក ៧

### ក-បុគ្គលទទួលខុសត្រូវពីបទឧក្រិដ្ឋនិងពីបទមជ្ឈិម ដែលប្រព្រឹត្តតាមសារពត៌មាន

មាត្រា ៥១-

ត្រូវជាប់ចោទជាអ្នកប្រព្រឹត្តដែលដល់ នូវទោស

ទាំងឡាយដែលឋិតក្នុងការបង្ក្រាបបទឧក្រិដ្ឋនិងបទមជ្ឈិម ដែលប្រព្រឹត្តតាមសារពត៌មាន ជនទាំងឡាយដែលរៀបរាប់ខាងក្រោមនេះ :

១- ចាងហ្វាងនៃការផ្សាយ ឬ អ្នកបោះពុម្ពផ្សាយ ដោយឥតគិតដល់អាជីវកម្ម ឬ នាមករណ៍របស់ខ្លួនឡើយ ,

២- បើគ្មានជនខាងលើនេះ គឺអ្នកនិពន្ធនាយក ឬ អ្នកនិពន្ធអត្ថបទត្រូវជាប់ចោទ

៣- បើគ្មានអ្នកប្រព្រឹត្ត គឺម្ចាស់រោងពុម្ពត្រូវជាប់ចោទ ។

៤- បើគ្មានម្ចាស់រោងពុម្ព គឺអ្នកលក់ អ្នកចែក និង អ្នកបិទផ្សាយ ត្រូវជាប់ចោទ ។

មាត្រា ៨២ -

កាលបើចាងហ្វាងនៃការផ្សាយ ឬ សហចាងហ្វាងនៃការផ្សាយ ឬ អ្នកបោះពុម្ពផ្សាយត្រូវជាប់ចោទ , ម្ចាស់អត្ថបទត្រូវជាប់ចោទប្រកាន់ ជាអ្នកសមគំនិត ។ ត្រូវជាប់ចោទប្រកាន់ជាអ្នកសមគំនិតដូចគ្នា គ្រប់ករណីទាំងអស់ ជនទាំងឡាយដទៃទៀត ដែលមាត្រា ៨២ និង ៨៣ នៃក្រមព្រហ្មទណ្ឌត្រូវអនុវត្តទៅលើ ។

មាត្រា ៥៣-

ម្ចាស់សារពត៌មាន ឬ ទស្សនាវដ្ដីទាំងឡាយ ត្រូវទទួលខុសត្រូវរួមគ្នា អំពីការកាត់ទោសឲ្យជនដែលរៀបរាប់ក្នុងមាត្រាទាំងពីរមុននេះ សងជាប្រាក់ទៅតតិយជន ស្របតាមក្រមរដ្ឋប្បវេណី ពីមាត្រា ៨១២ ទៅមាត្រា៨១៦ ។

មាត្រា ៥៤-

លើកលែងតែករណី ដែលអ្នកជាប់ចោទទទួលមរណភាពទៅហើយ ឬ ទទួលលើកលែងទោស ការប្ដឹងផ្នែករដ្ឋប្បវេណីពីបទបរិហារកេរ្តិ៍ មិនអាចធ្វើទៅបានដាច់ឡែកគ្នាពីបណ្ដឹងផ្នែកអាជ្ញាឡើយ ។

មាត្រា ៥៥-

សារពត៌មាន ឬ ទស្សនាវដ្ដី ដែលបានទទួលទោសពីបទល្មើសក្នុងរឿងសារពត៌មាន ចំពោះលើរូបម្ចាស់សារពត៌មាន ចាងហ្វាង ឬ សហចាងហ្វាងនៃការផ្សាយ ម្ចាស់រោងពុម្ព អ្នកនិពន្ធនាយក ឬ ចំពោះលើរូបអ្នកនិពន្ធអត្ថបទដែលបានចុះផ្សាយហើយ ដោយត្រូវកាត់ទោសជាបទមជ្ឈិម ទោះមិនទាន់ជាស្ថាពរក៏ដោយ ជាទោសគុកក្ដី ឬមួយត្រូវពិន័យជាប្រាក់ចំនួន ៥.០០០រៀលយ៉ាងតិចក្ដី ឬមួយត្រូវកាត់ឲ្យសងជម្ងឺចិត្តលើសពីចំនួនប្រាក់នេះក្ដី ក្នុងរយៈពេលបីថ្ងៃគត់ ដោយគិតពីថ្ងៃកាត់ទោសទៅ ហើយទោះជាមានការប្ដឹងជំទាស់ ឧទ្ធរណ៍ ឬការប្ដឹងសាទុក្ខសាលាវិនិច្ឆ័យក៏ដោយ ត្រូវបង់ប្រាក់តំកល់ទុក

នៅរតនាគារនូវប្រាក់ចំនួនស្មើនឹងសោហ៊ុយ ប្រាក់ពិន័យ និងប្រាក់សងជម្ងឺចិត្ត ប្រសិនបើតុលាការបានលំរេចដូច្នេះរួចហើយៗ ក្នុងករណីនៃការកាត់ទោសគុក ការតំកល់ទុកប្រាក់នេះ មិនត្រូវមានចំនួនតិចជាង ៥០.០០០រៀល ក្នុងសាលក្រមកាត់ទោសនីមួយ ៗ ទេ ។

បើគ្មានតំកល់ប្រាក់ទុក ក្នុងរយៈពេលកំណត់នោះទេ ការចេញផ្សាយសារពត៌មាន ត្រូវបញ្ឈប់ ។

ការចេញផ្សាយក្រោយនេះ នឹងត្រូវចាត់ទុកថាបានបន្តមកទៀត ទោះជាចេញផ្សាយក្រោមឈ្មោះមួយផ្សេងពីមុនក្តី ប្រសិនបើមានកើតហេតុការណ៍អ្វីមួយ ដែលបញ្ជាក់ថាការផ្សាយនេះ ជាការបន្តនៃការផ្សាយដែលត្រូវរលត់បាត់ទៅហើយ ដូចជាមានសហប្រតិបត្តិការ ពីបុគ្គលិកទាំងអស់ ឬ មួយភាគនៃសារពត៌មាន ឬ ទស្សនាវដ្តី ដែលបានឈប់ចេញផ្សាយទៅហើយ ដោយមិនបានតំកល់ប្រាក់នោះឬមួយមានសញ្ញាពីខាងក្រៅពីសារពត៌មានឬ ទស្សនាវដ្តី ឬកិការពិនិត្យទៅឃើញថា បន្ទាត់នយោបាយ ឬ ហេតុការណ៍ផ្សេងទៀត ដូចគ្នានឹងបន្ទាត់នយោបាយនៃសារពត៌មានដែលបិទទៅហើយ ។

មាត្រា ៥៦-

ក្នុងករណីនៃការប្រព្រឹត្តិល្មើស និងកថាខ័ណ្ឌ "២" និង "៣" នៃមាត្រា មុននេះ ម្ចាស់សារពត៌មាន ចាងហ្វាង និងសហចាងហ្វាងនៃការផ្សាយ អ្នកនិពន្ធនាយក ហើយនឹងម្ចាស់

ទោងពុម្ពនិងត្រូវជាប់ទោសគុក ពីប្រាំមួយខែ ដល់មួយឆ្នាំ ។

ជនដែលបានបន្តការផ្សាយនៃសារពត៌មាន ឬទស្សនាវដ្ដី ព្រមទាំងជនដែលបានបោះពុម្ពសារពត៌មាន ឬទស្សនាវដ្ដីនោះ នឹងត្រូវពិន័យជាប្រាក់រួមគ្នា តាមការអនុវត្តនៃកថាខណ្ឌមុននេះ ។

o

o o

## ១- អំពីនីតិក្រម

**មាត្រា ៥៧-**

បទឧក្រិដ្ឋទាំងឡាយដែលមានចែងក្នុងច្បាប់នេះ ត្រូវប្ដឹងទៅសាលាឧក្រិដ្ឋមានសមត្ថកិច្ច។បទមជ្ឈិមទាំងឡាយ ត្រូវប្ដឹងទៅសាលាមជ្ឈិម ។

**មាត្រា ៥៨-**

ក្រៅអំពីការកែប្រែ ដូចមានរៀបរាប់ខាងក្រោមនេះ នីតិក្រមនៃច្បាប់ធម្មតា ត្រូវយកមកអនុវត្តទៅចំពោះមុខសាលាកាត់ក្ដីទាំងអស់ និងចំពោះបទល្មើសទាំងអស់ ដែលមានចែងក្នុងច្បាប់នេះ :

១- ក្នុងករណី ការប្រមាថមាក់ងាយ ឬការបរិហារកេរ្ដិ៍ ចំពោះឯកជនទាំងឡាយ ការចោទប្រកាន់ទៅ

តុលាការនឹងត្រូវធ្វើឡើង លុះត្រាតែមានពាក្យប្ដឹងពីបុគ្គល
ដែលត្រូវគេបរិហារកេរ្ដិ៍ ឬ ត្រូវគេប្រមាថមាក់ងាយ ។

ក៏ប៉ុន្តែ ការចោទប្រកាន់ទៅតុលាការនឹងអាចធ្វើ
បានដោយឯកឯងពីក្រសួងអយ្យការ កាលបើការបរិហារកេរ្ដិ៍
ឬការប្រមាថមាក់ងាយនោះ ត្រូវបានប្រព្រឹត្តឡើងចំពោះ
ជនមួយក្រុមដែលមានជាតិសាសន៍មួយឬមានសាសនាមួយត្រឹមត្រូវ
តាមដើមកំណើតរៀងខ្លួន ក្នុងគោលបំណងញុះញង់ឱ្យកើត
ជាគំនុំគំគួនរវាងពលរដ្ឋទាំងឡាយ ឬរវាងបណ្ដាជនទាំង
ឡាយ ។

២- ក្នុងករណី ការប្រមាថមាក់ងាយ ឬការបរិហារ
កេរ្ដិ៍ចំពោះសាលាកាត់ក្ដីនិងតុលាការទាំងឡាយ, កងទ័ព,
អង្គការរដ្ឋទាំងឡាយព្រមទាំងរដ្ឋបាលសាធារណៈទាំងឡាយ
ការចោទប្រកាន់ទៅតុលាការ នឹងត្រូវធ្វើទៅបាន លុះណា
តែសាមីអង្គការទាំងនោះ បានជំនុំពិភាក្សា ហើយសំរេច
ចោទប្រកាន់ទៅតុលាការ ក្នុងអង្គប្រជុំមហាសន្និបាត ។ ប្រ-
សិនបើ អង្គការនោះ ឬ រដ្ឋបាលនោះ គ្មានមហាសន្និបាតទេ
ការចោទប្រកាន់ទៅតុលាការនឹងធ្វើទៅបាន លុះណាតែ
មានការប្ដឹងពីនាយកអង្គការឬពីរដ្ឋមន្ត្រីដែលអង្គការនោះ
ឬរដ្ឋបាលនោះឋិតនៅក្រោមឱវាទ ។

៣- ក្នុងករណី ការប្រមាថមាក់ងាយ ឬ ការបរិ-
ហារកេរ្ដិ៍ចំពោះសមាជិកមួយរូប ឬ ច្រើនរូបនៃសភាទាំង

ទ្រព្យរបស់រដ្ឋ , ការចោទប្រកាន់ទៅតុលាការ នឹងត្រូវធ្វើឡើង លុះណាតែមានការប្តឹងពីបុគ្គលមួយរូបឬពីបុគ្គលច្រើនរូប ជាសាមីជន ។

៤- ក្នុងករណី ការប្រមាថមាក់ងាយ ឬ ការបរិហារកេរ្តិ៍ ចំពោះមន្ត្រីរដ្ឋការទាំងឡាយ អ្នកកាន់អំណាច ឬ ភ្នាក់ងាររបស់អាជ្ញាធរសាធារណៈ ក្រៅពីរដ្ឋមន្ត្រី និង ពលរដ្ឋទាំងឡាយដែលទទួលបន្ទុកក្រសួងណាមួយ ឬ មានអាណត្តិរបស់រដ្ឋអ្វីមួយ , ការចោទប្រកាន់ទៅតុលាការ នឹងត្រូវធ្វើឡើងឬ មួយតាមការប្តឹងរបស់សាមីជនទាំងនេះ ឬ មួយដោយឯកឯង តាមការប្តឹងពីរដ្ឋមន្ត្រី ដែលសាមីជនធ្វើការក្រោមឱវាទ ។

៥- ក្នុងករណី ការប្រមាថមាក់ងាយ ឬ ការបរិហារកេរ្តិ៍ ចំពោះប្រមុខរដ្ឋ ឬ អ្នកតំណាងនៃប្រទេសណាមួយ ដែលមានការប្រស្រ័យទាក់ទងការទូតជាមួយសាធារណរដ្ឋខ្មែរ , ការចោទប្រកាន់ទៅតុលាការ នឹងត្រូវធ្វើឡើង ឬ មួយតាមសេចក្តីសុំពីសាមីជនដែលត្រូវប្រមាថមាក់ងាយ ឬ បរិហារកេរ្តិ៍ ឬ មួយតាមការប្តឹងពីក្រសួងការបរទេស ដែលសាមីជនបានសុំឱ្យប្តឹង ។

មាត្រា ៥៩-

ក្នុងរយៈវេលា ៣ ថ្ងៃ បន្ទាប់ពីតុលាការបានទទួលពាក្យបណ្តឹង ត្រូវចេញដីកាកោះ , ត្រូវឱ្យដំណឹងទៅជន

ជាប់ចោទនិងក្រសួងអយ្យការ , រីឯរយៈពេលចាប់ពីថ្ងៃប្រគល់ដីកាកោះនោះ ទៅដល់ថ្ងៃជំនុំជំរះក្តី ត្រូវកំណត់ត្រឹមចំនួន ១៥ ថ្ងៃគត់ ។

ក៏ប៉ុន្តែ ប្រសិនបើជាការប្រមាថមាក់ងាយ ឬជាការបរិហារកេរ្តិ៍ ដែលបានប្រព្រឹត្តក្នុងរយៈពេលបោះឆ្នោត ប្រឆាំងនឹងបេក្ខជនមួយរូប ដែលឈរឈ្មោះជ្រើសតាំងក្នុងមុខតំណែងណាមួយ នោះរយៈពេលខាងលើនេះ ត្រូវបង្រួញមកត្រឹម ៤៨ ម៉ោង , រីឯមាត្រា ៦១ និង ៦២ មិនត្រូវយកមកអនុវត្តទេ ។ រឿងក្តីនេះត្រូវជំនុំជំរះក្នុងពេល ៤៨ម៉ោង គិតតាំងពីកាលបរិច្ឆេទ ដែលបានទទួលពាក្យប្តឹងទៅតុលាការ។

មាត្រា ៦០-

ជនជាប់ចោទពុំអាចត្រូវចាប់ខ្លួន ឬ ឃុំឃាំងទេ លើកលែងតែក្នុងករណី មានការប្រព្រឹត្តិល្មើសទាំងឡាយ ដូចមានចែងក្នុងមាត្រា ២៧-២៨-២៩ និង ៣០នៃច្បាប់នេះ។

មាត្រា ៦១ -

ដើម្បីបង្ហាញភស្តុតាង អំពីភាពពិតនៃហេតុការណ៍ទាំងឡាយ ដែលត្រូវចាត់ទុកជាការបរិហារកេរ្តិ៍ ដូចមានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ជនជាប់ចោទ ក្នុងរយៈពេល ៧ ថ្ងៃ គិតតាំងពីកាលបរិច្ឆេទ ដែលបានទទួលដីកាកោះមក ត្រូវឲ្យដំណឹងទៅក្រសួងអយ្យការ និងភាគីដើម

ចោទ គឺ :

១- ហេតុការណ៍ទាំងឡាយដែលត្រូវចាត់ទុក ជាការបរិហារកេរ្តិ៍ ហើយដែលត្រូវមានភស្តុតាងបញ្ជាក់ថាជាការពិត ។

២- សេចក្តីចម្លងនៃសំណុំលិខិតបញ្ជូនទៅតុលាការ ។

៣- នាម អាសយដ្ឋាន និង អាជីវកម្មរបស់សាក្សីទាំងឡាយ ដែលទទួលការពារខ្លួន ។

មាត្រា ៦២-

ប្រាំថ្ងៃក្រោយពីបានទទួលដំណឹងពីជនជាប់ចោទ ហើយនៅគ្រប់ករណីក្នុងរយៈពេល បី ថ្ងៃ យ៉ាងតិចមុនពេលជំនុំជំរះ ភាគីដើមចោទ ឬ ក្រសួងអយ្យការ ដោយយោលទៅតាមកាលៈទេសៈ ត្រូវបញ្ជូនទៅភាគីចុងចោទនូវសេចក្តីចម្លងសំណុំលិខិត បញ្ជូនទៅតុលាការ ព្រមទាំងនាម អាសយដ្ឋាន និងអាជីវកម្មរបស់សាក្សី ដែលទទួលធ្វើការជំទាស់និងភស្តុតាង ។ បើពុំដូច្នោះទេ សិទ្ធិជំទាស់នឹងភស្តុតាង ត្រូវបដិសេធចោល។

មាត្រា ៦៣-

ចំពោះបទមជ្ឈិមទាំងឡាយ ដោយការប្រមាថមាក់ងាយ ឬ ការបរិហារកេរ្តិ៍ ការដកពាក្យប្តឹងនៃភាគីបវេណី និងត្រូវមានបច្ច័យបដិសេធចោលនូវការចោទប្រ-កាន់ទៅតុលាការ ។ ការដកពាក្យប្តឹង អាចធ្វើក្នុងរយៈ

ពេលដែលការសួរចម្លើយកំបាន និង ចំពោះមុខតុលាការកំពូល កំបាន ។

មាត្រា ៦៤-

ការបន្ថែមទោស និង ទណ្ឌកម្ម ពីបទល្មើសលើសជាថ្មី មិនត្រូវអនុវត្តទៅលើការប្រព្រឹត្តិល្មើសទាំងឡាយដូចមានចែងក្នុងច្បាប់នេះទេ លើកលែងតែមានករណីដែលបទល្មើសហោជាថ្មីពីរលើក ក្នុងមួយឆ្នាំ ។

ក្នុងករណីមានការប្រព្រឹត្តិនូវបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាច្រើន ដូចមានចែងក្នុងច្បាប់នេះ ត្រូវយកតែទោសមួយណា ដែលធ្ងន់ជាងគេបំផុតមកសំរេច ។

មាត្រា ៦៥-

ការប្តឹងចោទប្រកាន់ពីក្រសួងអយ្យការ និងការប្តឹងចោទប្រកាន់ពីភាគីបវេណី ដែលធ្វើឡើងចំពោះបទឧក្រិដ្ឋ បទមជ្ឈិម និងបទល្មើសទាំងឡាយដូចមានចែងក្នុងច្បាប់នេះ នឹងត្រូវរលត់ទៅឯកឯង បន្ទាប់ពីផុតរយៈវេលាប្រាំមួយខែគត់ចាប់តាំងពីថ្ងៃប្រព្រឹត្តបទល្មើស ឬ ចាប់ពីថ្ងៃដែលពាក្យចោទប្រកាន់តុលាការ ក្រោយបំផុត ប្រសិនបើបានធ្វើ ។

មាត្រា ៦៦-

បទបញ្ញត្តិទាំងឡាយនៃមាត្រា ១២៧ ដល់ ១៣៣

នៃក្រមព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តបានគ្រប់ករណី ដូចមានចែង ក្នុងច្បាប់នេះ ។

ក៏ប៉ុន្តែ ក្នុងករណីមានការសំរាលទោស ទោសដែល ត្រូវសំរេចនោះ ពុំអាចឲ្យតិចជាងពាក់កណ្តាលនៃទោស អប្បបរមា ដែលមានកំណត់ទុករួចមកហើយ ។

០

០ ០

## ជំពូក ៨

## អំពីរបបសារពត៌មាន ក្នុងពេលសង្គ្រាម

មាត្រា ៦៧-

ក្នុងករណី ដែលប្រជាជាតិតាំងនៅក្នុងភយន្តរាយ ឬ ក្នុងភាពសង្គ្រាម ក្នុងលក្ខខ័ណ្ឌទាំងឡាយ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ រដ្ឋមន្ត្រីក្រសួងការពារជាតិ មានអំណាចហាមឃាត់ មិនឲ្យផ្សាយពត៌មាន ឬ ការផ្សាយទាំងឡាយណា ដែលនាំឲ្យអន្តរាយដល់សន្តិសុខនៃកងទ័ព ឬ សន្តិសុខនៃបណ្តាជនទាំងឡាយ ដែលស្ថិតក្រោមការកំហែងគំរាមរបស់សត្រូវ ឬ របស់អ្នកផ្តើមអំណាច ឬមួយក្នុងករណីទូទៅ ដែលនាំឲ្យអន្តរាយ ដល់ការចាំបាច់នៃកិច្ចការពារជាតិ ។

ក្រៅពីនេះ រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចធ្វើ ទៅគ្រប់អង្គការសារពត៌មាននូវបញ្ជារឿងទាំងឡាយទាក់

ទាំងទៅនឹងលទ្ធិសុខដែនកិច្ចប្រតិបត្តិការសឹកទាំងឡាយ ហើយដែលនឹងអាចយកទៅផ្សាយជាពត៌មានបាន លុះត្រាតែមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងនេះជាមុន ។

មាត្រា ៦៨-

រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចចេញប្រកាសក្រសួងបញ្ជាឱ្យផ្អាកការផ្សាយជាបណ្ដោះអាសន្ន ឬ ជាស្ថាពរ នូវសារពត៌មាន ឬ ទស្សនាវដ្ដី ។

ដើម្បីចៀសវាងការលាតត្រដាង នូវការអាថ៌កំបាំងណាមួយដែនកិច្ចការពារជាតិ រដ្ឋមន្ត្រីក្រសួងការពារជាតិអាចចាត់ការបានតាមផ្លូវរដ្ឋបាល ឱ្យរឹបអូសជាមុននូវលិខិតជាលាយលក្ខណ៍អក្សរទាំងឡាយ លិខិតបោះពុម្ព ឬ សម្ភារៈទាំងឡាយផ្សេងទៀត សំរាប់ផ្សាយរឿងអាថ៌កំបាំងនេះ ។

មាត្រា ៦៩-

បទឧក្រិដ្ឋ និង បទមជ្ឈិមទាំងឡាយខាងសារពត៌មានដែលមានលក្ខណៈនាំឱ្យមានគ្រោះអន្តរាយដល់ការចាំបាច់ទាំងឡាយដែនកិច្ចការពារជាតិ ដូចមានចែងក្នុងមាត្រា ៦៧ ហើយដែលបានប្រព្រឹត្តក្នុងរយៈកាលដែលប្រជាជាតិតាំងក្នុងភយន្តរាយ ឬ ក្នុងភាពសង្គ្រាម ត្រូវបញ្ជូនទៅតុលាការសឹកជំនុំជំរះ ។

o

o o

## ជំពូក ៩

## សមាគម នៃ អ្នកសារពត៌មានខ្មែរ

**មាត្រា ៣០ –**

សមាគមនៃអ្នកសារពត៌មានខ្មែរ ជាអង្គការមួយ ប្រកបដោយលក្ខណៈច្បាប់ ហើយមានសិទ្ធិ :

១ - ធ្វើសកម្មភាពក្នុងឋានៈជាតំណាងនៃសារពត៌មាន ជាផ្លូវការ ,

២ - ធ្វើការទាក់ទងជាមួយអាជ្ញាធរនឹងអង្គការសារពត៌មាន ព្រមទាំងចូលរួមជាមួយសកម្មភាពទាំងឡាយដែលទាក់ទងនឹងសារពត៌មានផង ។

សមាសភាព មុខងារ និង ចំនួនសមាជិក គណៈកម្មការនាយក នៃសមាគមអ្នកសារពត៌មានខ្មែរ នឹងត្រូវរៀបរាប់ឡើង ដោយមហាសន្និបាតនៃអ្នកសារពត៌មានខ្មែរ ។

o o o

## ជំពូក ១០

## បទបញ្ញត្តិពិសេស

**មាត្រា ៣១ –**

ទិនានុប្បវត្តិ និង ទស្សនាវដ្តីទាំងឡាយ ដែលមាន

រួចមកហើយ នៅពេលដាក់ច្បាប់នេះឱ្យអនុវត្ត នឹងត្រូវទុកថាជាការផ្សាយត្រឹមត្រូវតាមលក្ខណៈច្បាប់ ។ ក៏ប៉ុន្តែចាងហ្វាងនៃការផ្សាយនៃទិនានុប្បវត្តិ និង ទស្សនាវដ្ដីទាំងនោះត្រូវបំពេញសំណុំលិខិតនៃពាក្យបណ្ដឹងជូនពត៌មានរបស់ខ្លួនពីមុនឱ្យបានគ្រប់សព្វ ក្នុងរយៈវេលាពីរខែ គិតតាំងពីថ្ងៃប្រកាសឱ្យប្រើបច្ចុប្បន្នច្បាប់នេះ ។

បើហួសកំណត់វេលា ពីរ ខែ ខាងលើនេះទៅ ទិនានុប្បវត្តិ ឬ ទស្សនាវដ្ដីណាមួយមិនបានបំពេញសំណុំលិខិតដូចមានចែងក្នុងកថាខ័ណ្ឌខាងលើទេ នឹងត្រូវផ្អាកការផ្សាយរបស់ខ្លួន ។

មាត្រា ៧២-

ត្រូវទុកជាមោឃៈ បទបញ្ញត្តិទាំងឡាយ ដែលមានពីមុន ហើយផ្ទុយនឹងបច្ចុប្បន្នច្បាប់នេះ ។

- ច ប់ -

# ORDONNANCE PROMULGANT LE CODE DE LA PRESSE

No 39/72/PRK

LE PRESIDENT
DE LA REPUBLIQUE KHMERE

Vu la Constitution de la République Khmère notamment en son article 7;

Vu l'Ordonnance n° 1/71-CE du 18 Octobre 1971 régissant les questions relevant du domaine de la Loi;

Le Conseil des Ministres entendu,

ORDONNE:

**ARTICLE UNIQUE.** – Est promulgué le Code réglementant le régime de la presse en Répubique Khmère appelé "Code de la Presse" dont les dispositions sont annexées à la présente Ordonnance.

**ARTICLE 2.** – Cette Ordonnance est déclarée d'urgence.

Fait à Phnom Penh, le 27 juin 1972

Signé: **LON NOL**

# CODE DE LA PRESSE

-=-=-=-

## CHAPITRE 1er

## DISPOSITIONS GENERALES

Article 1er.-

Toute manifestation de pensée par la voie de la presse est libre.

La censure de la presse est interdite.

Article 2.-

L'exercice de la liberté de presse ne doit pas porter atteinte à l'honneur personnel, à la sécurité nationale ou aux bonnes moeurs.

Tout citoyen doit éviter d'abuser de ce droit pour troubler l'ordre public.

Article 3.-

L'exercice de la liberté de presse ne peut être suspendu que s'il y a état d'urgence, état de siège ou si la nation est proclamée en danger ou en état de guerre dans les conditions prévues par l'article 22 de la Constitution.

Article 4.-

Le présent Code règlemente le régime de la presse en République Khmère.

o o o

## CHAPITRE II

### L'imprimerie et la librairie sont libres.

**Article 5.-**

L'Imprimerie et la Librairie sont libres. Toutefois, le métier d'imprimeur est interdit aux étrangers.

**Article 6.-**

Tout écrit rendu public, à l'exception des ouvrages dits "de ville" ou "bilboquets" portera l'indication du nom et du domicile de l'imprimeur, à peine, contre celui-ci, d'une amende de 7.000 à 70.000J.

La distribution des imprimés qui ne porteraient pas la mention exigée au paragraphe précédent est interdite et la même peine est applicable à ceux qui contreviendraient à cette interdiction.

Une peine d'emprisonnement de six mois à un an pourra être prononcée si, dans les douze mois précédents, l'imprimeur ou le distributeur a été condamné pour délit de même nature.

° ° °

## CHAPITRE III

## DE LA PRESSE PERIODIQUE : DROIT DE PUBLICATION, GERANCE, DECLARATION ET DEPOT

### Article 7.-

Tout journal ou écrit périodique doit avoir un propriétaire, un directeur de publication et un rédacteur en chef.

Le propriétaire peut être lui-même directeur de publication et ou rédacteur en chef.

Lorsque le directeur de la publication jouit de l'immunité parlementaire dans les conditions prévues à l'article 54 de la Constitution, il doit désigner un co-directeur de la publication choisi parmi les personnes ne bénéficiant pas de l'immunité parlementaire.

### Article 8.-

Tout journal ou écrit périodique, publié en langue nationale, peut être publié après une déclaration au ministre de l'Information suivant les dispositions du présent Code.

### Article 9.-

Le propriétaire, le directeur de publication, le co-directeur de publication et le rédacteur en chef doivent :

a - Etre de nationalité khmère.

b - Avoir 25 ans révolus à la date du dépôt du dossier de déclaration.

c - Avoir la jouissance de leurs droits civils et ne pas être privé de leurs droits civiques par aucune condamnation judiciaire.

Le directeur de publication, le co-directeur de publication et le rédacteur en chef doivent en outre avoir un diplôme de journalisme, ou un diplôme de baccalauréat en Droit ou un diplôme équivalent, ou un certificat attestant qu'ils ont travaillé comme rédacteurs pendant au moins deux ans dans un ou plusieurs journaux, agence de presse, ou encore qu'ils ont été fonctionnaires du Cadre supérieur, ou directeur ou rédacteurs en chef d'un journal ou écrit périodique pendant au moins un an.

Article 10. -

La déclaration au ministre de l'Information prévue à l'article 8 doit être faite par le directeur de publication.

Le dossier de déclaration comprend :

1 - Une déclaration en triple exemplaire avec signature dûment légalisée du directeur de publication indiquant :

- le titre du journal ou écrit périodique, son mode de publication, son but et sa ligne de conduite;